ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១២៨

ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣

**នាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

<u>សាលដីកា</u>

លេខ: ៣១៩

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះរួមក្រុមជាសាធារណៈនៅថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៉ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | វៀល | មួន | ជាចៅក្រម |
| ៣-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៤-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចិរយា | ជាចៅក្រមរបាយការណ៍ |
| ៦-លោក | យស់ | សួខឿន | ជាចៅក្រម |
| ៧-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៨-លោក | ប៉ែន | សាវឿន | ជាចៅក្រម |
| ៩-លោក | គង់ | គីរុន | ជាចៅក្រម |
| លោក | **សុខ** | **ម៉ៅ** | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

លោក **ឈុន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ១៩៩"ឈ"ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍រវាង :

- ដើមចោទឈ្មោះ ក្អួត ឡា ,សម វិទ្ធិ, កោះ សំបៀន(ជាម្ចាស់បណ្តឹងសាទុក្ខ) តំណាងឱ្យប្រជាជន ១៦គ្រួសារ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

មានមេធាវីលោក កែត ឃឹ...

- និងចុងចម្លើយឈ្មោះ **សៀន សាម៉េត** (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ មុខរបរធ្វើនគរបាល ទីលំនៅសព្វថ្ងៃភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

មានមេធាវី លោក ឈី សម្បត្តិ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដី ១៦ឡូត៍ .

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៤៦៤ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះ កត ឡា ,កោះ សំបៀន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៩៩"ឈ"ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៨ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៦-៨-១៩៩៨ របស់ឈ្មោះកត ឡា ,ឈ្មោះកោះ សំបៀន និង ឈ្មោះកាក់ វិទ្ធិ បានប្តឹងពីឈ្មោះសៀន សាម៉េត ពីបទលួចដីចំនួន ១៦ឡូត៍ របស់គ្រួសារខ្លួន ទៅលក់ឱ្យអ្នកដទៃ នៅក្នុងខែសីហា ឆ្នាំ១៩៩៨ ក្នុងនោះដីរបស់លោក កត ឡា ៥ឡូត៍ ដីរបស់លោកកោះ សំបៀន ៨ឡូត៍ និងដីរបស់លោក កាត វិទ្ធិ ៣ឡូត៍ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៤ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៨ របស់ដើមចោទឈ្មោះ កត ឡា ,កោះ សំបៀន,កាក វិត ជាតំណាង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ឱ្យដើមចោទទាំង ១៦រូប មានសិទ្ធិគ្រប់គ្រងលើដីលំនៅដ្ឋានចំនួន ១៦ឡូត៍ ដែលបានសុំកាន់កាប់រួចហើយ ជាកម្មសិទ្ធិស្របច្បាប់ បន្ទាប់ពីសាលក្រមនេះមានអនុភាពអនុវត្តន៍។

៣-កាត់យកប្រាក់ប្រដាប់ក្តីចំនួន ៧០០០៛ ដែលដើមចោទបានបង់រួចហើយ និងឱ្យភាគីដើមចោទបង់ពន្ធសមាមាត្រតាមតំលៃដីដែលសៀន សាម៉េត បានលក់ឱ្យឃុំពីឆ្នាំ១៩៩៦ មួយឡូត៍ ៩០០បាត សរុប ១៤.៤០០បាត អត្រាត្រូវបង់១% ស្មើ ១៤៤បាត "មួយរយសែសិបបួនបាត" តាមបញ្ញត្តិច្បាប់ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី ទុកសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រម ៕

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកសៀន សាម៉េត ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៤ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦២"ច"ចុះថ្ងៃទី២៧ខែមេសាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះសៀន សាម៉េត ទុកជាត្រឹមត្រូវតាមទំរង និង គតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៩៤ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ទាំង ១៦ឡូត៍ ស្ថិតនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឱ្យទៅឈ្មោះសៀន សាម៉េត កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៤-ទុកសិទ្ធិឱ្យដើមចោទប្តឹងទារប្រាក់ពីរដ្ឋអំណាចដែលបានលក់ដីឱ្យដើមចោទវិញ

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍១៣.០០០៛ គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ដីកាកោះ ៥០០០៛ អាជ្ញាធរតុលាការ ៥០០០៛ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ១% លើដីទំនាស់នេះ ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៨៦ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ របស់ លោក កត ឡា និង លោកកោះ សំបៀន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦២"ច" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៧១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ របស់ លោក សៀន សាម៉េត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦២"ច" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទាមទារជំងឺចិត្ត និងសោហ៊ុយខាតបង់ពេលវេលាចំនួន ៣០លានរៀល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ១៨៦ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ របស់លោក កត ឡា និងកោះ សំបៀន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលបណ្ដឹងសាទុក្ខលេខ ១៧១ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ របស់លោកសៀន សាម៉េត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

៣-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៦២"ច" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន៣៨.០០០រ ដែលលោកសៀន សាម៉េត បានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្ដីនឹងពន្ធហ្លឹងចំនួន៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប១៩.០០០រ នៅសល់១៩០០០រ បង្វិលជូនលោកសៀន សាម៉េត វិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ខែឧសភា ឆ្នាំ២០០១ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៩៩"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីសាលាឧទ្ធរណ៍លេខ ៤០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០១ តាមអំណាចសាលដីការដ្ឋប្បវេណីរបស់តុលាការកំពូលលេខ ៧៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៩៤ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣-ប្រគល់ដី ១៦ឡូត៍ ស្ថិតនៅខាងកើត ឈៀងខាងជើងវត្តស្រះត្រាច ភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឱ្យទៅឈ្មោះសៀន សាម៉េត កាន់កាប់ ជាកម្មសិទ្ធិ ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រ គឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ្លឹង ២៥៥០រ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រ និង ចំណាយលើអាជ្ញាធរតុលាការ ៥០០០រ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ បង្គាប់ឱ្យ...

ដើមចោទបង់ពន្ធសមាមាត្រ១% លើថ្លៃដីទំនាស់ ។ ប្រាក់ពន្ធសមាមាត្រនេះ ដាក់ចូលថវិការដ្ឋ៨០% និងត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ ចំពោះមុខតំណាងចុងចំលើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៤៦៤ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះ កត ឡា ,កោះ សំបៀន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៩៩"ឈ"ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះកត ឡា និង កោះ សំបៀន។

បានឃើញសារណាតបចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះសៀន សាម៉េត ។

បានឃើញសាលដីការដ្ឋប្បវេណីរបៀបលេខ ២០៣ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបធ្វើការអង្កេតបន្ថែម ហើយបើក្នុងករណីចាំបាច់ ចាត់ចៅក្រមប្រឹក្សាតុលាការកំពូលចុះពិនិត្យ ដល់ទីតាំងដីទំនាស់ ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៣ ខែកញ្ញាឆ្នាំ២០០៤ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះតុលាការកំពូលបានចុះពិនិត្យត្រឹមត្រូវហើយ សូមសំរេចចុះ ។

បានស្តាប់ចំលើយរបស់ឈ្មោះកោះ សំបៀន នាពេលសវនាការថា : ខ្លួនតំណាងអោយប្រជាជនទាំង ១៦គ្រួសារ ខ្លួនមិនសុខចិត្តនឹងការសំរេចសាលាឧទ្ធរណ៍ ព្រោះដីនេះរដ្ឋអំណាចបានបែងចែកឱ្យពួកខ្លួនមានចំនួន ១៦ឡូត៍ មេឃុំខៀវ រដ្ឋា ឱ្យប្រជាជនចេញថ្លៃកាប់ឆ្ការព្រៃចំនួន៤០០បាត ឱ្យសៀន សាម៉េត ១០០បាត ថ្លៃវាស់វែងប្រជាជនចេញប្រាក់ឱ្យ ទូច សាខន ចំនួន ៥៦០០បាត ដើម្បីឱ្យសៀន សាម៉េត ថ្លៃកាប់ឆ្ការព្រៃរួចហើយ ស្មើដីចំនួន ១៦ឡូត៍នេះ មានសាក្សីដឹងឮឃើញច្បាស់ ទូច សាខន ប្រគល់លុយឱ្យសៀន សាម៉េត ផង ។ក្រោយមកប្រជាជន ១៦គ្រួសារទៅកាប់ឆ្ការព្រៃដោយខ្លួនឯង ពេលដីស្អាតហើយ បានសៀន សាម៉េត យកបង្គោលទៅបោះហើយថា ដីរបស់ខ្លួនវិញ ឯដីណាំ និងអណ្តូងទឹករបស់សៀន សាម៉េត ទើបដាំ និងធ្វើក្រោយពេលដីមានទំនាស់ទេ ។ ពេលប្រជាជន ១៦គ្រួសារ ប្រគល់លុយឱ្យទូច សាខន១ ប្រគល់អោយ សៀន...

---

សាម៉េត នៅស្នាក់ការភូមិ មានគណៈកម្មការវាស់វែង បានឃើញនោះ ពុំបានធ្វើកំណត់ហេតុប្រគល់ទទួលជាលាយល័ក្ខអក្សរអ្វីទេ ។ ក្រោយមកទើបដឹងថាដីទំនាស់របស់សៀន សាម៉េត ។ ពេលដែលតុលាការកំពូលចុះពិនិត្យដីទំនាស់ ខ្លួនសុំឱ្យតុលាការកំពូលវាស់ដីទំនាស់សារឡើងវិញនោះ ដោយសារ ដំបូងវាស់ខុស ព្រោះពេលគណៈកម្មការវាស់វែងលើកមុនមានទុកផ្លូវ ចំពោះដីឡូត៍ពួកខ្លួនមានលេខប៉ុន្មាន ខ្លួនពុំចាំអស់ទេ ខ្លួនតំណាងឱ្យប្រជាជន១៦គ្រួសារសុំជួយរកយុត្តិធម៌និងមេត្តាផ្តល់សិទ្ធិឱ្យ ពួកខ្លួនបានកាន់កាប់ និងបានដីទំនាស់ទាំង ១៦គ្រួសារ, ១៦ឡូត៍ ធ្វើកម្មសិទ្ធិតាមផ្លូវច្បាប់ផង ។

បានស្តាប់ចំលើយរបស់ឈ្មោះសៀន សាម៉េត នាពេលសវនាការថា : ដីទំនាស់ខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៩១ មកដល់ឆ្នាំ១៩៩៧ ខៀវ រដ្ឋា ជាមេឃុំ សម័យនោះបានសុំចែកទិញដីខ្លួនយកចែកឱ្យប្រជាជននិងថាចេញថ្លៃកាប់ឆ្ការ ក្រោយមកមិនទាន់បានទិញប្រគល់លុយឱ្យខ្លួន និងពុំទាន់មានការវាស់វែងបែងចែកឱ្យប្រជាជនអ្វីផង ខៀវ រដ្ឋា ធ្លាក់ពីតំណែងទៅ ខ្លួនក៏ពុំដែលបានទទួលលុយថ្លៃដីពីខៀវ រដ្ឋា ដែរ ។ ដីនេះខ្លួនជាអ្នកកាប់ឆ្ការព្រៃដោយខ្លួនឯង និងបានជួលកម្មករកាប់ មានរដ្ឋអំណាចទទួលស្គាល់ការកាន់កាប់របស់ខ្លួនផង ។ តំណាងដើមចោទនិយាយកុហកគាត់មិនស្គាល់ដីខ្លួនផង ដីនេះពុំមានការបែងចែកជាឡូត៍អ្វីទេ ។ កន្លងមករហូតដល់សព្វថ្ងៃ ខ្លួនមានឯកសារបញ្ជាក់ថា ខ្លួនជាអ្នកកាន់កាប់ និងបង្កបង្កើនផលធ្វើស្រែលើដីនេះ ។ សំណូមពរតំកល់ការសំរេចរបស់សាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែត ឃី ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : ទំនាស់កើតឡើងឆ្នាំ១៩៩៨ ក្រោយពីពលរដ្ឋ១៦គ្រួសារបានទិញដីពីអាជ្ញាធរមូលដ្ឋានមានតំលៃ ៩០០បាត ក្នុងមួយឡូត៍មានទំហំ ១២ម x ២០ម សរុប ១៦ឡូត៍ ។ ចុងចំលើយឆ្លើយពីក្រោមមកថា លោក ខៀវ រដ្ឋា ទិញដីខ្លួនចែកឱ្យប្រជាជនមែន ហើយប្រជាជនទាំង ១៦គ្រួសារបានប្រគល់លុយឱ្យសៀន សាម៉េត រួចហើយ ខ្លួនមានឯកសារបញ្ជាក់ថា សៀន សាម៉េត បានទទួលប្រាក់ចំនួន ៦០០០បាត រួចហើយ ប្រាក់នេះលើសថ្លៃដីទៅទៀត មានសាក្សីដឹងឮផង កាលបើប្រជាជនបានប្រគល់លុយហើយ បែរជា សៀន សាម៉េត យកដីវិញ ជាការខុសច្បាប់ ប្រជាជនទាមទារដីតែ ១៦ឡូត៍ទេ សុំតុលាការផ្តល់សិទ្ធិឱ្យប្រជាជនបានគ្រប់គ្រងដីទាំង ១៦ឡូត៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ឈី សម្បត្តិ ជាមេធាវីការពារឱ្យចុងចំលើយ បានលើកឡើងថា : សុំមេត្តាតំកល់សាលដីកាសាលាឧទ្ធរណ៍ចុះ ព្រោះទំនាស់កើតឡើងពីទំនាក់ទំនងរវាងប្រជាជន១៦គ្រួសារ និង ទូច សាខន,ខៀវ រដ្ឋា ទេ កន្លងមក សៀន សាម៉េត បានយល់ព្រមលក់ដីឱ្យខៀវ រដ្ឋា មែន តែ សៀន សាម៉េត មិនទាន់បានទទួលលុយថ្លៃដីនោះទេ ឯថា...

កូនក្ដីខ្លួន បានទទួលលុយនោះ គឺមិនពិតទេ ទូច សាខន ក៏ដូចសៀន សាម៉េត មិនដែលទទួលស្គាល់ថា ប្រគល់លុយថ្លៃដីឱ្យ សៀន សាម៉េត ទេ បើ កោះ សំបៀន ឆ្លើយថា ដីទំនាស់របស់សៀន សាម៉េត ហើយម្ដេចទៅនិយាយទិញដីពីទូច សាខន និងខៀវ រដ្ឋា ទៅវិញ ប្រជាជនទាំង១៦គ្រួសារ គ្មាននីតិសម្បទាទទួលដីទាំង១៦ឡូត៍ទេ ពេលតុលាការកំពូលចុះទៅមើល ដើមចោទចង្អុលខុសទីតាំងដីទាំងអស់ ហើយជាន់លើដីគេ ។ សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវហើយ ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចំលើយរបស់តំណាងប្រជាជន ១៣គ្រួសារ និង លោក សៀន សាម៉េត និងសេចក្ដីសន្និដ្ឋានរបស់មេធាវីរបស់គូភាគី .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៤៦៤ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះក្អួត ឡា ,ឈ្មោះកោះ សំបៀន តំណាងឱ្យប្រជាជន ១៣គ្រួសារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកធ្វើការជំនុំជំរះរួមក្រុម ទាំងអង្គច្បាប់ និង អង្គហេតុបាន តាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា ២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីបានផងដែរ ។

- យល់ឃើញថា ភាគីដើមចោទបានលើកឡើងដោយស្របគ្នាថា ដីនេះពួកខ្លួនបានទំនាក់ទំនងទិញពីរដ្ឋអំណាចមូលដ្ឋាន ដោយបានប្រគល់ប្រាក់ថ្លៃលក់រួចហើយ ទៅឱ្យលោកខៀវ រដ្ឋា ជាអតីតមេឃុំប៉ោយប៉ែត តាមរយៈលោកទូច សាខន ដែលចំណុចនេះនឹងស្របតាមចំលើយរបស់លោកទូច សាខន ដែលបានឆ្លើយនៅតុលាការកំពូលតាមកំណត់ហេតុចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ដែរ តែទាក់ទងនឹងការអះអាងនេះ លោក ខៀវ រដ្ឋា បានដោះសារតាមកំណត់ហេតុចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០២ ថា ដីទាំង១៦ឡូត៍នេះ ខ្លួនមិនបានលក់ឱ្យប្រជាជនទាំង១៦គ្រួសារនោះឡើយ ហើយក៏មិនបានឱ្យលោកទូច សាខន យកដីទាំងនេះលក់ឱ្យប្រជាជនទាំង១៦គ្រួសារនោះដែរ និងក៏មិនដែលបានទទួលថ្លៃលក់ដីទាំងនេះដែរ គឺបានត្រឹមតែបង្កើតគណកម្មការវាស់វែងប៉ុណ្ណោះ ។

- យល់ឃើញថា តាមកំណត់ហេតុសួរតទល់ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ លោក ទូច សាខន ក៏ដូចជាលោកសៀន សាម៉េត ដែរ បានឆ្លើយស្របគ្នាថា កិច្ចព្រមព្រៀងទិញ-លក់ដីពិតជាបានបង្កើតឡើងមែន ហើយភាគីអ្នកទិញបានទទួលតែបង្កាន់ដៃប៉ុណ្ណោះ រីឯដីលក់គ្មានទេ និង...

ម៉្យាងទៀតថ្វីត្បិតតែដីលោក សៀន សាម៉េត ដែលជាដីទំនាស់ ស្ថិតក្នុងគំរោងសំរាប់លក់អោយប្រជាជនមែន ក៏ប៉ុន្តែពុំទាន់បានធ្វើការវាស់វែង និង កំណត់ច្បាស់ថា ឈ្មោះណាត្រូវបានកន្លែងណាឡើយ ដូចនេះទាំងចំលើយលោកទូច សាខន ក៏ដូចជាចំលើយរបស់លោកខៀវ រដ្ឋា ដែរ គឺបានផ្តល់ផលប្រយោជន៍ឱ្យដល់ភាគីលោក សៀន សាម៉េត ជាភាគីចុងចោទហើយ ។

- យល់ឃើញថា មានភស្តុតាងដែលបញ្ជាក់ថា ដីទំនាស់ដែលមានទំហំ ១៦ឡូត៍ ស្ថិតនៅក្នុងមូលដ្ឋានភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីមុនពេលមានទំនាស់ ដីនេះត្រូវបានលោកសៀន សាម៉េត ចូលធ្វើការកាន់កាប់ រុករានជំរះដី ហើយនៅក្នុងរវាងឆ្នាំ១៩៩៦-១៩៩៧ ក៏កើតមានទំនាក់ទំនងទិញ-លក់ រវាងលោកសៀន សាម៉េត និងអាជ្ញាធរមូលដ្ឋាន ដើម្បីយកដីនេះ ចែកចាយបន្តទៅឱ្យប្រជាជនចំនួន ១៦គ្រួសារ ដែលជាភាគីដើមចោទ ដែលមានលោក ទូច សាខន ជាអ្នកប្រមូលប្រាក់ថ្លៃលក់ពីប្រជាជនទាំង ១៦គ្រួសារ តែពុំមានភស្តុតាងថា លោកសៀន សាម៉េត ដែលជាម្ចាស់ដី បានទទួលប្រាក់ពីការទិញលក់នេះទេ ដូចនេះទំនាក់ទំនងគតិយុត្តក្នុងការទិញ-លក់ នេះ មានត្រឹមតែការព្រមព្រៀងប៉ុណ្ណោះ តែមិនទាន់កើតមានអានុភាពសុពលផ្ទេរកម្មសិទ្ធិពីភាគីម្ចាស់ដីទៅភាគីអ្នកទិញនោះដែរ ដែលស្របតាម មាត្រា ១៨២ នៃច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើតាមក្រឹត្យ-ច្បាប់ លេខ ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ភាគីលោកសៀន សាម៉េត នៅតែជាកម្មសិទ្ធិករលើដីទំនាស់នេះដដែល ។

- យល់ឃើញថា ការដែលលោកកោះ សំបៀន លើកឡើងនាសវនាការនេះថា មានសាក្សីដឹងឮច្បាស់លាស់ថា លោកទូច សាខន បានប្រគល់ប្រាក់ថ្លៃដីដែលប្រមូលពីប្រជាជនចំនួន ៥៦០០បាត ឱ្យលោកសៀន សាម៉េត ជាការពុំត្រឹមត្រូវទេ ពីព្រោះថា តាមចំលើយរបស់លោកទូច សាខន ផ្ទាល់ដែលបានឆ្លើយនៅតុលាការកំពូលតាមកំណត់ហេតុចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៥ ថា ប្រាក់ដែលប្រមូលបានពីប្រជាជននោះ លោកបានប្រគល់ឱ្យលោកមេឃុំខៀវ រដ្ឋា ។

- យល់ឃើញថា លោកទូច សាខន ពិតជាបានទទួលប្រាក់ថ្លៃដីពីប្រជាជនទាំង ១៦ គ្រួសារមែន ហើយតាមចំលើយរបស់លោកក្នុងកំណត់ហេតុចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ថា បានប្រគល់ប្រាក់នេះ ឱ្យទៅលោកមេឃុំខៀវ រដ្ឋា តែត្រូវលោកខៀវ រដ្ឋា ដោះសារមិនបានទទួលឡើយ ដូចនេះគប្បីតុលាការកំពូលរក្សាសិទ្ធិឱ្យប្រជាជនទាំង១៦គ្រួសារ ក្នុងការប្តឹងទាមទារសំណងពីបុគ្គលទាំងឡាយ ដែលបានទទួលផលនេះ ។

- យល់ឃើញថា សាលដីកាលេខ ១៩៩"ឈ"ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ពិតជាបានសំរេចតាមការចង្អុលបង្ហាញនៃសាលដីកាលេខ ២៩៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ របស់តុលាការកំពូលរួចហើយ តែភាពត្រឹមត្រូវនេះមានទៅលើតែចំណុចទាក់ទង...

---

និងដីទំនាស់ចំនួន ១៣ឡូត៍ ដែលត្រូវបានទាមទារដោយតំណាងឈ្មោះ ក្អួត ឡា និងឈ្មោះ កោះ សំបៀន តែប៉ុណ្ណោះទេ រីឯដីចំនួន៣ឡូត៍ទៀត ដែលត្រូវទាមទារដោយឈ្មោះភាត វិត ជាការសំរេចលើសពីការចង្អុលបង្ហាញនៃសាលដីកាតុលាការកំពូលហើយ ព្រោះថា ក្នុងសំអាងហេតុសាលដីការបស់តុលាការកំពូលបានចាត់ទុកថា សាលដីកាលើកទី១ របស់សាលាឧទ្ធរណ៍លេខ ៦២"ច" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ បានចូលជាស្ថាពរមានអានុភាពអនុវត្តចំពោះដីទាំង ០៣ឡូត៍នេះហើយ ដោយលោកភាត វិត មិនបានធ្វើបណ្តឹងសាទុក្ខឡើយ ដូចនេះបណ្តឹងទាមទារទាក់ទងនឹងដី ៣ឡូត៍នេះ មានអានុភាពអាជ្ញាអស់ជំនុំហើយ ។

- យល់ឃើញថា សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីឡើងវិញ តាមសាលដីការដ្ឋប្បវេណីលេខ១៩៩"ឈ"ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៣ នោះពិតជាមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ខ្លះ ហើយខុសខ្លះ ។

**ហេតុដូចនេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី**

១-ទទួលបណ្តឹងសាទុក្ខលើកទី២លេខ៤៦៤ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះ ក្អួត ឡា,ឈ្មោះកោះ សំបៀន តំណាងឱ្យប្រជាជន ១៣គ្រួសារ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ១៩៩"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែកម្មវត្ថុទំនាស់ដី ៣ឡូត៍ ដោយត្រូវបានសាលដីការដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ របស់តុលាការកំពូលបានចាត់ទុកថាបានចូលស្ថាពររួចហើយ ។

៣-រក្សាសិទ្ធិឱ្យប្រជាជនទាំង ១៦គ្រួសារ ដែលបានប្រគល់ប្រាក់ឱ្យទៅលោក ទូចសាខន ក្នុងការប្តឹងទាមទារសំណងពីបុគ្គលដែលបានទទួលផលនេះ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក សៀន សាម៉េត បានបង់នៅតុលាការកំពូលចំនួន ១៩០០០៛ គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតំរូវឱ្យភាគីដើមចោទ សងប្រាក់ចំនួន ១៩០០០៛ នេះទៅចុងចំលើយវិញ ។

**និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួន ១% តាមការកំណត់របស់សាលាឧទ្ធរណ៍ ។**

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥ ។

*សាលដីការដ្ឋប្បវេណីលេខ ៣១៩ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់តុលាការកំពូល ។*